មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## ម.ស.ម.ក ចេញផ្សាយរបាយការណ៍អំពីការវាយតម្លៃលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ នេះ គម្រោងសង្កេតការណ៍សវនាការរបស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយរបាយការណ៍របស់ខ្លួនលើកដំបូងអំពីការវាយតម្លៃលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍ ("របាយការណ៍")។ នេះគឺជារបាយការណ៍លើកទី៧ ដែលបានចេញផ្សាយដោយគម្រោងសង្កេតការណ៍សវនាការ និងជារបាយការណ៍លើកទី១ដែលបានលើកឡើងអំពីការអនុវត្តន៍របស់សាលាឧទ្ធរណ៍។ របាយការណ៍នេះ បង្ហាញនូវទិន្នន័យនៃសវនាការជំនុំជម្រះចំនួន ២០៤ ដែលគម្រោងបានសង្កេតចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤។ ទិន្នន័យទាំងអស់អាចរកបាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា ដែលជាគេហទំព័រទទួលបានជ័យលាភី និងបង្ហោះដោយ ម.ស.ម.ក តាមរយៈ ៖ http://tmp.sithi.org/។

ស្របពេលដែលសាលាឧទ្ធរណ៍ជាទូទៅគោរពតាមនីតិវិធី ដែលសំដៅដល់ការធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្តីព្រួយបារម្ភមួយចំនួននៅតែកើតមានក្នុងបញ្ហាសំខាន់ៗជាសារជាតុបន្ថែមទៀត។ ក្រៅពីមានការព្រួយបារម្ភជាទូទៅពាក់ព័ន្ធទៅនឹងកង្វះឯករាជ្យភាពរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") បញ្ហាសំខាន់ៗដែលត្រូវដោះស្រាយជាអាទិភាពរួមមាន ការខកខានមានលក្ខណៈជាប្រព័ន្ធរបស់ចៅក្រមក្នុងការប្រាប់ និងពន្យល់ដល់ពិរុទ្ធជនអំពីសិទ្ធិរបស់អ្នកទាំងនោះ ព្រមទាំងអវត្តមានរបស់ពិរុទ្ធជននៅពេលសវនាការរបស់ខ្លួនមានចំនួនច្រើន។ បន្ថែមពីលើនេះទៀត ការវិភាគទិន្នន័យបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញនៅមានលក្ខណៈខ្វះខាត និងគំរាមកំហែងដល់សិទ្ធិទទួលបានការផ្តន្ទាទោសឲ្យហួសពីវិមតិសង្ស័យ ព្រមទាំងបង្ហាញថា សាលដីកាក្នុងសំណុំរឿងភាគច្រើនមិនបានប្រកាសដោយយោងមាត្រាច្បាប់ ឬភស្តុតាងនោះទេ។

អនុសាសន៍លើកឡើងក្នុងរបាយការណ៍រួមមាន ការអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បង្កើនសមត្ថភាពរបស់សាលាឧទ្ធរណ៍ ដើម្បីមានលទ្ធភាពដោះស្រាយប្រព័ន្ធគ្រប់គ្រងសំណុំរឿង បញ្ចៀសការពន្យារពេលសវនាការ និងគ្រប់គ្រងសំណុំរឿងថ្មីៗឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ របាយការណ៍នេះ ក៏អំពាវនាវឲ្យក្រុមប្រឹក្សាធម្មនុញ្ញបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការតុលាការ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាទៅសភាជាតិវិញ ហើយស្នើឲ្យសភាជាតិកែប្រែច្បាប់ទាំងនេះ ដើម្បីធានាឲ្យច្បាប់ទាំងនេះគោរពនូវគោលការណ៍ឯករាជ្យភាពរបស់តុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា។

**លោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"ម.ស.ម.ក មានសេចក្តីរីករាយតាមរយៈកិច្ចសហប្រតិបត្តិការក្នុងន័យស្ថាបនាជាមួយនឹងសាលាឧទ្ធរណ៍ ដែលទទួលបានលទ្ធផលវិជ្ជមានមួយចំនួនដូចជា ការបិទផ្សាយកាលបរិច្ឆេទសវនាការជាសាធារណៈនៅខាងក្រៅបន្ទប់សវនាការក្នុងការគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងការព្យួរខិត្តប័ណ្ណរបស់ ម.ស.ម.ក រៀបរាប់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងបន្ទប់រង់ចាំរបស់ពិរុទ្ធជន។ តែយ៉ាងណាក្តី នៅមានចំណុចព្រួយបារម្ភផ្សេងៗទៀត ដែលគួរតែត្រូវបានដោះស្រាយជាបន្ទាន់ និងងាយស្រួល ដូចជា ការធានាឲ្យចៅក្រមពន្យល់ពីសិទ្ធិដល់ពិរុទ្ធជន និងសម្របសម្រួលជាមួយមន្ត្រីពន្ធនាគារឲ្យបានរឹតតែល្អប្រសើរ ដើម្បីធានាថាពិរុទ្ធជននឹងមានវត្តនៅពេលសវនាការ។ ប្រការនេះ នឹងផ្តល់ជាគំរូវិជ្ជមានសម្រាប់តុលាការនានានៅកម្ពុជា។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានរំលោភបំពានជាប្រចាំនៅកម្ពុជា ប៉ុន្តែខ្ញុំជឿជាក់ថា បញ្ហាទាំងនេះនៅតែអាចប្រសើរឡើងក្នុងពេលឆាប់ៗ ហើយការចាំបាច់តែមួយគត់គឺការខិតខំអនុវត្តន៍នីតិរដ្ឋប្រកបដោយប្រសិទ្ធភាព។"*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ឌុច ពិសិដ្ឋ តាមរយៈទូរសព្ទ ៖ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬ អ៊ីម៉ែល ៖ duchpiseth@cchrcambodia.org ឬលោកស្រី អេលីស ធីលែត ជំនួយការបច្ចេកទេស ម.ស.ម.ក តាមរយៈទូរសព្ទ៖+៨៥៥ (០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល ៖ elise.tillet@cchrcambodia.org។**

**ចប់**

**បណ្ណាធិការ ៖**

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ទទួលបានកិច្ចឧបត្ថម្ភគាំទ្រពីសំណាក់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក("ជំនួយពីពលរដ្ឋអាមេរិក") តាមរយៈវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចិមប្រទេស និងពីការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ខ្លឹមសារ

នេះគឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ជំនួយពីពលរដ្ឋអាមេរិក រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬ វិទ្យាស្ថានគ្រប់គ្រងបូព៌ា បស្ចិម ឬ ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនោះទេ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្មពិភពលោក (OMCT) ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងជ័យលាភីបានទទួលពានរង្វាន់ផ្នែកទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនឡែន ក្នុងរដ្ឋប្រ៊ីសបែន ប្រទេសអូស្ត្រាលី។